ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ: ០៤៤/១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*រាជធានីភ្នំពេញ ថ្ងៃ ចន្ទ ៦រោច ខែ ជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២*

*ត្រូវនឹងថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៨*

# សេចក្ដីជូនដំណឹង

## ស្តីពីការដាក់ឱ្យដំណើរការ ប្រព័ន្ធជួញដូរចល័ត (Mobile Trading System) សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សមាជិក វិនិយោគិន អ្នកសារព័ត៌មាន និងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ផ.ម.ក នឹងដាក់ឱ្យដំណើរការបឋមនូវ ប្រព័ន្ធជួញដូរចល័ត (Mobile Trading System) សំរាប់ការជួញដូរមូលបត្រកម្មសិទ្ធិ ចាប់ពីថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨ នេះតទៅ។ ដើម្បីប្រើប្រាស់ប្រព័ន្ធនេះ វិនិយោគិនត្រូវមានគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រណាមួយ ដែលជាសមាជិករបស់ ផ.ម.ក និងបានចុះឈ្មោះជាមួយ ផ.ម.ក ដើម្បីផ្តល់សេវាប្រព័ន្ធជួញដូរចល័តនេះ។ ប្រព័ន្ធនេះនឹងដាក់ឱ្យប្រើប្រាស់ដោយឥតគិតថ្លៃនៅក្នុងអំឡុងពេលនៃការដាក់ឱ្យដំណើរការបឋមនេះ និងត្រូវបន្តរយៈពេលមួយឆ្នាំទៀត គិតចាប់ពីថ្ងៃដាក់ឱ្យប្រើប្រាស់ជាផ្លូវការដែលនឹងជម្រាបជូននាពេលក្រោយ។

ប្រព័ន្ធជួញដូរចល័ត គឺជាប្រព័ន្ធជួញដូរតាមអ៊ិនធើណេត ដែលត្រូវបានអភិវឌ្ឍឡើងក្រោមការជួយគាំទ្រពីសំណាក់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (កយក) ក្នុងគោលដៅជួយសម្រួល និងជំរុញការជួញដូរមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជីនៅ ផ.ម.ក។ ដំណើរការនៅលើ web browser ដែលមានស្រាប់នៅលើស្មាតហ្វូន និងថេបប្លេត ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យវិនិយោគិនធ្វើការដាក់បញ្ជាជួញដូរ កែប្រែ និងលុបចោលបញ្ជារបស់ខ្លួនបានដោយខ្លួនឯង ក៏ដូចជាពិនិត្យមើលបញ្ជា និងទិន្នន័យជួញដូរកន្លងមកផងដែរ។ បន្ថែមពីនេះវិនិយោគិនក៏អាចតាមដានមើលទិន្នន័យទីផ្សារ សេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និង របស់ ផ.ម.ក. ព្រមទាំងព័ត៌មានដទៃផ្សេងទៀតផ្តល់ដោយសមាជិករបស់ ផ.ម.ក. ដែលមានសារៈសំខាន់សម្រាប់ការសម្រេចចិត្តវិនិយោគ។

វិនិយោគិនដែលមានបំណងចុះឈ្មោះប្រើប្រាស់ប្រព័ន្ធនេះ អាចស្នើដំណើរការគណនីនៃប្រព័ន្ធជួញដូរចល័តនេះដោយខ្លួនឯង ដោយគ្រាន់តែចូលទៅកាន់ https://mts.csx.com.kh រួចអនុវត្តតាមការណែនាំ ឬទាក់ទងដោយផ្ទាល់ទៅកាន់ក្រុមហ៊ុនមូលបត្ររបស់ខ្លួនដើម្បីស្វែងរកជំនួយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក ផ.ម.ក. តាមរយៈទូរស័ព្ទ លេខ (+៨៥៥) ២៣ ៩៥ ៨៨៨៨ ឬអ៊ីម៉ែល market@csx.com.kh។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

CSX Cambodia Securities Exchange